BNK Financial Group

# របាយការណ៍ប្រចាំឆ្នាំ ២០២២

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេនខេស៊ី (ខេមបូឌា) ភីអិលស៊ី
BNKC (Cambodia) Microfinance Institution Plc.

BNK Financial Group

# របាយការណ៍ប្រចាំឆ្នាំ ២០២២

BNK Financial Group

# មាតិកា

## អំពីក្រុមហ៊ុន

០៨ តួលេខសំខាន់ៗ
០៩ ព័ត៌មានគ្រឹះស្ថាន
១០ ភាគទុនិក
១១ ក្រុមប្រឹក្សាភិបាល
១២ ទស្សនៈវិស័យ | បេសកកម្ម | គោលដៅយុទ្ធសាស្ត្រ
១៣ ចំណាប់អារម្មណ៍របស់អគ្គនាយកប្រតិបត្តិ

## ប្រតិបត្តិការរបស់យើង

១៦ សាខា
១៨ ផលិតផល
២០ កម្មវិធីទូរស័ព្ទដៃ « BNKC Mobile App »

## ក្រុមការងាររបស់យើង

២២ រចនាសម្ព័ន្ធគ្រឹះស្ថាន
២៣ គណៈគ្រប់គ្រងកំពូល
២៤ គណៈគ្រប់គ្រង
២៨ ការអភិវឌ្ឍសមត្ថភាពបុគ្គលិក
៣០ ទំនួលខុសត្រូវផ្នែកសង្គម
៣១ សិក្ខាសាលាថ្នាក់គ្រប់គ្រង

## របាយការណ៍សវនកម្មឯករាជ្យ

៣៣ របាយការណ៍សវនកម្មឯករាជ្យ

# អំពីក្រុមហ៊ុន

# តួលេខសំខាន់ៗ

២០២០ ២០២១ ២០២២

## សាខា




## បុគ្គលិក




## អតិថិជន




## សមតុល្យផលប័ត្រឥណទានសរុប

(US$, Thousand)




## ប្រាក់ចំណេញសុទ្ធ

(US$, Thousand)



# ព័ត៌មានគ្រឹះស្ថាន




២០
សាខា

១០,៦៥០
ចំនួនអតិថិជន

១៨ ខេត្ត
១,០០១ ឃុំ
៣,៧២៥ ភូមិ
តំបន់ប្រតិបត្តិការ

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេនខេស៊ី (ខេមបូឌា) ភីអិលស៊ី** ដែលមានឈ្មោះដើមថាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ខេប៊ីអេសស៊ី (ខេមបូឌា) ភីអិលស៊ី ជាសាជីវកម្មទទួលខុសត្រូវមានកម្រិតដែលបានបង្កើតឡើងនៅថ្ងៃទី០៧ ខែមីនា ឆ្នាំ ២០១៤ ហើយបានទទួលអាជ្ញាប័ណ្ណពីធនាគាជាតិនៃកម្ពុជានៅ ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៥។ គ្រឹះស្ថានទទួលបានការវិនិយោគ ១០០% ពីក្រុមហ៊ុនមេ BNK Capital Co,. Ltd. មានមូលដ្ឋាននៅទីក្រុងប៊ូសាន នៃសាធារណរដ្ឋកូរ៉េ នូវដើមទុនចំនួន ២០លានដុល្លារសហរដ្ឋអាមេរិក។ គោលបំណងចំបងរបស់គ្រឹះស្ថាន គឺផ្តល់សេវាហិរញ្ញវត្ថុដ៏ល្អបំផុត ជូនប្រជាជនកម្ពុជាប្រកប ដោយទំនួលខុសត្រូវ និងតម្លាភាព ព្រមទាំងចូលរួមក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនៃប្រទេសកម្ពុជា។ លើសពីនេះទៅទៀត ប៊ីអេនខេស៊ី កំពុងផ្តល់នូវឱកាសការងារជូនដល់និយោជិតដែលមានបំណងចង់អភិវឌ្ឍន៍សមត្ថភាព និងជំនាញឲ្យចូលរួមបម្រើការងារក្នុងគ្រឹះស្ថានដើម្បីភាពរីកចម្រើននាពេលអនាគត។


ការិយាល័យកណ្តាលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេនខេស៊ី
(អាគារប៊ីរ៉េ រាជធានីភ្នំពេញ)




# BNK Capital តែងតែនៅជាមួយ លោកអ្នកជានិច្ច។

ក្រុមហ៊ុន ប៊ីអេនខេ ខាប់ភីតាល់ គឺជាក្រុមហ៊ុនគ្រួសារជាមួយធនាគារ ប៊ូសាន និង ធនាគារ យ៉ុងណាំ ជាក្រុមហ៊ុនបុត្រសម្ព័ន្ធនៃ BNK Financial Group ដែលផ្តល់ជូននូវផលិតផល និងសេវាកម្មផ្នែកហិរញ្ញវត្ថុជាច្រើនប្រភេទរួមមាន ឥណទានយានយន្ត (បង់រំលស់ ជួល កម្ចី) ឥណទានផ្ទាល់ខ្លួន ឥណទានដាក់ទ្រព្យធានា បង់រំលស់សម្ភារៈប្រើប្រាស់ និងហិរញ្ញវត្ថុសាជីវកម្មជាដើម-ល-។

ក្រុមហ៊ុន ប៊ីអេនខេ ខាប់ភីតាល់ ត្រូវបានបង្កើតឡើងតាំងពីឆ្នាំ ២០១០ ហើយបានអភិវឌ្ឍនខ្លួនជាក្រុមហ៊ុនមូលធនពណ៌ខៀវ (Blue-Chip) ដែលតំណាងឱ្យបណ្តាញអាជីវកម្មទូទាំងប្រទេស ហើយមានទ្រព្យសម្បត្តិប្រតិបត្តិការរហូតដល់ទៅ ៣ លានលានវ៉ុន ក្នុងរយៈពេលត្រឹមតែ ៤ ឆ្នាំប៉ុណ្ណោះ។

ប៊ីអេនខេ ខាប់ភីតាល់ រក្សាយ៉ាងខ្ជាប់ខ្ជួននូវការតាំងចិត្តក្នុងការបំពេញតម្រូវការហិរញ្ញវត្ថុចម្រុះរបស់អតិថិជន។ លើសពីនេះ ក្រុមហ៊ុន ប៊ីអេនខេ ខាប់ភីតាល់ បានពង្រីកបណ្តាញទីផ្សាហិរញ្ញវត្ថុរបស់ខ្លួននៅក្នុងប្រទេសដែលកំពុងរីកចម្រើននាពេលថ្មីៗនៅអាស៊ីអាគ្នេយ៍ តាមរយៈការបោះជំហានចូលទៅក្នុងទីផ្សាឥណទានខ្នាតតូចក្នុងប្រទេសមីយ៉ាន់ម៉ាឡាវ និង ប្រទេសកម្ពុជា នៅក្នុងឆ្នាំ២០១៤ និងពង្រឹងកេរ្តិ៍ឈ្មោះ ក្នុងនាមជាគ្រឹះស្ថានហិរញ្ញវត្ថុដែលមានឯកទេសខាងផ្នែកឥណទាន។

ក្រុមហ៊ុន ប៊ីអេនខេ ខាប់ភីតាល់ ប្តេជ្ញាបង្កើតនូវសេវាកម្មហិរញ្ញវត្ថុជាច្រើនប្រភេទ ដោយផ្អែកលើធនធានមនុស្សប្រកបដោយវិជ្ជាជីវៈ និងចំណេះដឹងផ្នែកហិរញ្ញវត្ថុ ហើយខិតខំប្រឹងប្រែងឱ្យអស់ពីសមត្ថភាពដើម្បីផ្តល់ជូនអតិថិជននូវសេវាកម្មហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព និងភាពច្នៃប្រឌិត។

ក្រុមហ៊ុន ប៊ីអេនខេ ខាប់ភីតាល់ ក៏មានឆន្ទៈក្នុងការក្លាយជាក្រុមហ៊ុនមួយដែលផ្តល់អាទិភាពទៅលើសេចក្តីពេញចិត្តរបស់អតិថិជន ជាក្រុមហ៊ុនដែលយកចិត្តទុកដាក់ខ្លាំងលើការលើកកម្ពស់សុខុមាលភាពសង្គម និងផ្តល់ការលើកទឹកចិត្តទៅដល់បុគ្គលិករបស់ខ្លួន។ ក្រុមហ៊ុន បានដាក់ចេញនូវរាល់កិច្ចខិតខំប្រឹងប្រែងដើម្បីក្លាយជាក្រុមហ៊ុនហិរញ្ញវត្ថុដ៏ល្អបំផុតដែលមានសមត្ថភាពជាស្ថាប័នហិរញ្ញវត្ថុឈានមុខគេក្នុង និងក្រៅប្រទេសនាពេលអនាគតស្របតាមចក្ខុវិស័យគ្រប់គ្រងកម្រិតមធ្យម/រយៈពេលវែងរបស់ BNK Financial Group «ជាក្រុមហ៊ុនហិរញ្ញវត្ថុឈានមុខគេលើពិភពលោក/ក្នុងតំបន់»។

BNK Capital

១00%

ការវិនិយោគ

៣៨០

ពាន់លាន

ដើមទុនដែលបានចុះបញ្ជី (WON)

# ក្រុមប្រឹក្សាភិបាល



លោក KIM SUNGHWA
ប្រធានក្រុមប្រឹក្សាភិបាល



លោក KIM SOONJO
សមាជិកក្រុមប្រឹក្សាភិបាល



លោក PARK BYOUNGSOO
សមាជិកក្រុមប្រឹក្សាភិបាល



លោក HA JEONGSOO
សមាជិកក្រុមប្រឹក្សាភិបាល



លោក អ៊ីវ ប៉ូលី
សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ

# ទស្សនៈវិស័យ | បេសកកម្ម | គោលដៅយុទ្ធសាស្រ្ត

## ទស្សនវិស័យ

ផ្តល់នូវសេវាកម្មផ្នែក
ហិរញ្ញវត្ថុល្អបំផុតជូនទៅ
ប្រជាជនកម្ពុជាដើម្បីការរីក
ចម្រើនប្រកបដោយនិរន្តរភាព

## បេសកកម្ម

លើកស្ទួយកម្រិតជីវភាពរបស់ប្រជា
ពលរដ្ឋក្នុងប្រទេសកម្ពុជា
ពង្រឹងតម្លៃរបស់អតិថិជន បុគ្គលិក
ម្ចាស់ភាគហ៊ុន និងសង្គមជាតិ

## គោលដៅយុទ្ធសាស្រ្ត

បង្កើតផលិតផលផ្សេងៗ
និងពង្រីកតំបន់ទីផ្សារ

បង្កើនសុចរិតភាព និង
ប្រាក់ចំណេញ

បង្កើនគុណភាពនៃទ្រព្យ
សកម្មដោយពង្រឹង
ការគ្រប់គ្រងហានិភ័យ



BNKC ជាដៃគូអាជីវកម្មដ៏ល្អរបស់លោកអ្នក

# ចំណាប់អារម្មណ៍របស់អគ្គនាយកប្រតិបត្តិ



**លោក KIM SOON JO**

អគ្គនាយកប្រតិបត្ត

ជម្រាបសួរ! ខ្ញុំបាទ KIM Soonjo ជាអគ្គនាយកប្រតិបត្តរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេនខេស៊ី (ខេមបូឌា) ភីអិលស៊ី។
ជាដំបូង ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអតិថិជនដែលតែងតែគាំទ្រគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេនខេស៊ី ដោយការទុកចិត្ត និងក្តីស្រលាញ់មិនងាករេ។

គ្រឹះស្ថាន ប៊ីអេនខេស៊ី ត្រូវបានបង្កើតឡើងក្នុងខែមីនា ឆ្នាំ ២០១៤។ មកទល់បច្ចុប្បន្ននេះ តាមរយៈ ទំនុកចិត្តដ៏រឹងមាំរបស់អតិថិជន គ្រឹះស្ថានបានឈរជើងធ្វើប្រតិបត្តិការនៅប្រទេសកម្ពុជាដោយមានអតិថិជន សរុប ១០,៦៥០នាក់ និងសាខាប្រតិបត្តិការចំនួន ២០ សាខា។

គ្រឹះស្ថាន ប៊ីអេនខេស៊ី បានរួមចំណែកក្នុងការអភិវឌ្ឍនសេដ្ឋកិច្ចក្នុងស្រុក តាមរយៈការធ្វើប្រតិបត្តិការ លើវិស័យមីក្រូហិរញ្ញវត្ថុជាអាទិភាពចម្បង ដោយមានការផ្តល់សេវាកម្មកម្ចីផ្សេងៗដូចជា កម្ចីអាជីវកម្ម កម្ចីទិញផ្ទះ កម្ចីកសិកម្ម និងកម្ចីគ្មានទ្រព្យធានា។

គ្រឹះស្ថាននឹងបន្តអភិវឌ្ឍនខ្លួនដើម្បីភាពរីកចម្រើនរួមគ្នាជាមួយអតិថិជនក្រោមពាក្យស្លោក «ប៊ីអេនខេស៊ីជា ដៃគូអាជីវកម្មល្អបំផុតរបស់អ្នក»។ បុគ្គលិកយើងទាំងអស់នឹងប្រឹងប្រែងឱ្យអស់ពីសមត្ថភាពក្នុងការក្លាយខ្លួន ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលផ្តល់ សេវាហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិតបែបឌីជីថល និងផ្តោតសំខាន់ លើអតិថិជនជាចម្បងស្របតាមយុគសម័យឌីជីថល។

លើសពីនេះទៅទៀត គ្រឹះស្ថានបាននិងកំពុងចូលរួមចំណែកក្នុងសកម្មភាពសង្គមផ្សេងៗតាមរយៈកាតព្វកិច្ចទទួលខុសត្រូវសង្គម។ បុគ្គលិកទាំងអស់គ្រប់ជាន់ថ្នាក់នឹងអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាម គោលការណ៍ និងសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា ត្បូយ៉ាងរក្សាឱ្យបាននូវតម្លាភាព សីលធម៌របស់បុគ្គលិក ទំនួលខុសត្រូវ និងការគ្រប់គ្រងប្រកបដោយក្រមសីលធម៌ ក្នុងន័យព្យាយាមធ្វើយ៉ាងណាឱ្យ ប៊ីអេនខេស៊ី ក្លាយជាគ្រឹះស្ថានដែលឈរលើគ្រឹះនៃភាពស្មោះត្រង់ និងជំនឿទុកចិត្ត។

ខ្ញុំសូមជូនពរអតិថិជនរបស់គ្រឹះស្ថាន ប៊ីអេនខេស៊ីទាំងអស់ប្រកបដោយសុខភាពល្អ សុភមង្គល និងការរីកចម្រើនជានិច្ចនិរន្ត។ សូមអរគុណ!

ពីខ្ញុំអគ្គនាយកប្រតិបត្តិ

**KIM SOONJO**

អគ្គនាយកប្រតិបត្តិ

BNK Financial Group

# ប្រតិបត្តិការរបស់យើង



# សាខា



### ទីស្នាក់ការកណ្តាល
អាគារប៊ីវ៉េ មហាវិថីព្រះនរោត្តម
សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ៖ ០២៣ ២១៣ ៩០០



### សាខាស្រុកឧដុង្គ
ភូមិឧត្តុង្គ ឃុំវាំងចាស់
ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ
ទូរស័ព្ទ៖ ០២៥ ២១៨ ២៨២



### សាខាស្រុកអង្គស្នួល
ភូមិចុងបង្គោល ឃុំបែកចាន
ស្រុកអង្គស្នួល ខេត្តកណ្តាល
ទូរស័ព្ទ៖ ០២៣ ៧២៩ ៧១១



### សាខាស្រុកបរសេដ្ឋ
ភូមិផ្សារស្លាបលែង ឃុំស្វាយរំពារ
ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ
ទូរស័ព្ទ៖ ០២៥ ៩០០ ១១០



### សាខាស្រុកកណ្តាលស្ទឹង
ភូមិសៀមរាប ឃុំសៀមរាប
ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល
ទូរស័ព្ទ៖ ០២៤ ៩០០ ១៣៥



### សាខាស្រុកថ្ពង
ភូមិមនោរម្យ ឃុំមនោរម្យ
ស្រុកថ្ពង ខេត្តកំពង់ស្ពឺ
ទូរស័ព្ទ៖ ០២៥ ៩០០ ១១៩



### សាខាស្រុកខ្សាច់កណ្តាល
ភូមិព្រែកតាមាក់ ឃុំព្រែកតាមាក់
ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល
ទូរស័ព្ទ៖ ០២៤ ៩០០ ១៣១



### សាខាស្រុកជើងព្រៃ
ភូមិប៉ាណា ឃុំសូទិព្វ
ស្រុកជើងព្រៃ ខេត្តកំពង់ចាម
ទូរស័ព្ទ៖ ០៤២ ៩០០ ១១០



### សាខាក្រុងច្បារមន
ភូមិបុរីកម្មករ សង្កាត់រកាធំ
ក្រុងច្បារមន ខេត្តកំពង់ស្ពឺ
ទូរស័ព្ទ៖ ០២៥ ២១០ ២២៩



### សាខាស្រុកត្រាំកក់
ភូមិព្រៃរំដេង ឃុំអង្គតាសោម
ស្រុកត្រាំកក់ ខេត្តតាកែវ
ទូរស័ព្ទ៖ ០៣២ ២១៥ ២១៥




**សាខាស្រុកបាទី**
ភូមិព្រហែក ឃុំសូភី
ស្រុកបាទី ខេត្តតាកែវ
ទូរស័ព្ទ៖ ០៣២ ៩០០ ១១៨




**សាខាក្រុងបាត់ដំបង**
ភូមិកម្មករ សង្កាត់ស្វាយប៉ោ
ក្រុងបាត់ដំបង ខេត្តបាត់ដំបង
ទូរស័ព្ទ៖ ០៥៣ ៩៥២ ៩៥២




**សាខាស្រុកសំរោង**
ភូមិព្រៃទទឹង ឃុំសំរោង
ស្រុកសំរោង ខេត្តតាកែវ
ទូរស័ព្ទ៖  ០៣២ ៩០០ ១១៩




**សាខាក្រុងសេរីសោភ័ណ**
ភូមិ៣ សង្កាត់ព្រះពន្លា
ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ
ទូរស័ព្ទ៖ ០៥៤ ៩០០ ១១២



**សាខាស្រុកឈូក**
ភូមិឈើទាល ឃុំឈូក
ស្រុកឈូក ខេត្តកំពត
ទូរស័ព្ទ៖ ០៣៣ ៩០០ ១៣៥




**សាខាក្រុងប៉ោយប៉ែត**
ភូមិប៉ាលិលេយ្យ២ សង្កាត់ប៉ោយប៉ែត
ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ
ទូរស័ព្ទ៖ ០៥៤ ៩០០ ១១០




**សាខាក្រុងកំពត**
ភូមិស្វាយធំ សង្កាត់ក្រាំងអំពិល
ក្រុងកំពត ខេត្តកំពត
ទូរស័ព្ទ៖ ០៣៣ ៩០០ ១១០




**សាខាស្រុកពាមរក៍**
ភូមិព្រែករាំង ឃុំពន្លិចប្រសាទ
ស្រុកពាមរក៍ ខេត្តព្រៃវែង
ទូរស័ព្ទ៖ ០៤៣ ៩០០ ១១៨




**សាខាក្រុងសៀមរាប**
ភូមិទ្រាំង សង្កាត់ស្លក្រាម
ក្រុងសៀមរាប ខេត្តសៀមរាប
ទូរស័ព្ទ៖ ០៦៣ ៧៥៦ ៧២២




**សាខាស្រុកស្វាយអន្ទរ**
ភូមិស្វាយអន្ទរទី១ ឃុំស្វាយអន្ទរ
ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង
ទូរស័ព្ទ៖ ០៤៣ ៩០០ ១១៩

# ផលិតផល

### ឥណទាន សម្រាប់អាជីវកម្មទូទៅ

ជាប្រភេទឥណទានឯកត្តជន ដែលបង្កើតឡើងសម្រាប់អតិថិជនដែលមានបំណងចង់បង្កើតអាជីវកម្មថ្មី ឬពង្រីកអាជីវកម្ម ដើម្បីសម្រួលដល់ប្រភពចំណូលរបស់ពួកគាត់។ កម្ចីអាចផ្តល់បានរហូតដល់ ៥០,០០០ ដុល្លារអាមេរិកឬ សមមូលជាប្រាក់រៀលខ្មែរ និងរយៈពេលកម្ចីរហូតដល់ ៧២ខែ។

### ឥណទាន កសិកម្ម

ជាប្រភេទឥណទានឯកត្តជន ដែលផ្តល់សម្រាប់អតិថិជនដែលមានបំណងចង់ចាប់ផ្តើម ឬពង្រីកសកម្មភាពកសិកម្ម ឬរកចំណូលពីវិស័យកម្មមានដូចជា ធ្វើ ស្រែ ចំការ ចិញ្ចឹមសត្វ នេសាទ ជាដើម។ កម្ចីអាចផ្តល់បានរហូតដល់ ៣០,០០០ ដុល្លារអាមេរិក ឬសមមូលជាប្រាក់រៀលខ្មែរ និងរយៈពេលកម្ចីរហូតដល់៧២ខែ។

### ឥណទាន គេហដ្ឋាន

ជាប្រភេទឥណទានឯកត្តជនដែលផ្តល់ជូនដល់អតិថិជនដែលមានបំណងចង់ធ្វើការទិញនូវអចលនទ្រព្យ ដូចជា ដីសម្រាប់សាងសង់ផ្ទះ ទិញនូវគេហដ្ឋានក្នុងសុបន្តិ Condo/Apartment ជាដើម។ ចំនួនកម្ចីនិងរយៈពេលខ្ចីមានលក្ខណៈបត់បែនតាម ការចរចារ និងស្ថានភាពរបស់អិថិជន។

### ឥណទាន សម្រាប់កែលម្អគេហដ្ឋាន

ជាប្រភេទឥណទានឯកត្តជនដែលផ្តល់សម្រាប់អតិថិជនដែលត្រូវការដើមទុនក្នុងការជួសជុល ឬរៀបចំកែលម្អនូវគេហដ្ឋានរបស់ពួកគាត់អោយបានល្អប្រសើរ។ កម្ចីអាចផ្តល់បាន រហូតដល់ ១៥,០០០ ដុល្លារអាមេរិក ឬសមមូលជាប្រាក់រៀលខ្មែរ និងរយៈពេលកម្ចីរហូតដល់ ៧២ខែ។

### ឥណទាន រថយន្ត

ជាប្រភេទឥណទានឯកត្តជនដែលផ្តល់សម្រាប់អតិថិជនដែលមានបំណងចង់ធ្វើការទិញនូវរថយន្តសម្រាប់ប្រើប្រាស់ក្នុងក្រុមគ្រួសាររបស់ពួកគាត់ និងមិនមែនសម្រាប់ធ្វើអាជីវកម្ម។ កម្ចីអាចផ្តល់បានរហូតដល់ ៣០,០០០ ដុល្លារ ឬសមមូលជាប្រាក់រៀលខ្មែរ និងរយៈពេលកម្ចីរហូតដល់ ៧២ខែ។

## ចំណាប់អារម្មណ៍អតិថិជន



នាងខ្ញុំជាអ្នកប្រកបអាជីវកម្មលក់ដូរមួយរូប។ ក្នុងអំឡុងពេលស្វែងរកកម្ចីដើម្បីទិញទំនិញស្តុកទុក ខ្ញុំក៏បានស្គាល់ពីផលិតផលកម្ចីសម្រាប់ម្ចាស់អាជីវកម្មរបស់ប៊ីអេនខេស៊ី ស្របពេលដែលខ្ញុំកំពុងស្វែងរកប្រាក់កម្ចី ដើម្បីឲ្យអាជីវកម្មរបស់ខ្ញុំមានភាពរីកចម្រើន។ ខ្ញុំគេងមិនលក់ព្រោះតែខ្ញុំបារម្ភអំពីបញ្ហាលុយបន្ទាន់ដែលមិនអាចដោះស្រាយបាន ក៏ប៉ុន្តែដោយសារតែបានប៊ីអេនខេស៊ី ទើបខ្ញុំអាចដោះស្រាយបានទាន់ពេលវេលា។ ជារួមមកដោយសារតែបានប៊ីអេនខេស៊ី ទើបធ្វើឲ្យខ្ញុំដូចជាមានសុភមង្គលឡើងវិញ។ សូមឲ្យបុគ្គលិកដែលជួយប្រឹក្សាយោបល់យ៉ាងរួសរាយរាក់ទាក់នៅក្នុងស្ថាប័នទាំងអស់ មានសុភមង្គលនៅថ្ងៃចុងសប្តាហ៍នេះផងដែរ។ សូមអរគុណ! **(វ៉ាន់ថៃ / សាខាក្រុងសិរីសោភ័ណ)**

### ឥណទានទិញសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃ

ជាប្រភេទឥណទានឯកត្តជនដែលមិនត្រូវការទ្រព្យសម្រាប់ធានា។ អតិថិជនអាចប្រើប្រាស់កម្ចីក្នុងការទិញនូវឧបករណ៍អេឡិចត្រូនិចផ្សេងៗ ដូចជាទូរស័ព្ទដៃ កុំព្យូទ័រយួរដៃ ជាដើម។ កម្ចីអាចផ្តល់បានរហូតដល់ ១០,០០០ ដុល្លារអាមេរិក ឬសមមូលជាប្រាក់រៀលខ្មែរ និងរយៈពេលកម្ចីរហូតដល់ ៣៦ខែ។

### ឥណទានសូឡា

ជាប្រភេទឥណទានឯកត្តជន ឬឥណទានអាជីវកម្មដែលផ្តល់សម្រាប់អតិថិជនដែលមានបំណងចង់តម្លើង ប្រព័ន្ធសូឡានៅទីតាំងអាជីវកម្ម ឬលំនៅដ្ឋាន។ ឥណទាននេះមានទំហំរហូតដល់ ៣០,០០០ ដុល្លារអាមេរិក ឬសមមូលនឹងប្រាក់រៀលខ្មែរ និងមានរយៈពេលកម្ចីរហូតដល់ ៧២ខែ។

### ឥណទានសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន

ជាប្រភេទឥណទានឯកត្តជនដែលផ្តល់សម្រាប់អតិថិជនដែលមានបំណងចង់ធ្វើការទិញនូវឧបករណ៍ផ្សេងៗ សម្រាប់បម្រើក្នុងក្រុមគ្រួសារ ឬរបស់របរផ្ទាល់ខ្លួនពួកគាត់។ កម្ចីអាចផ្តល់បានរហូលដល់ ១៥,០០០ ដុល្លារអាមេរិក ឬសមមូលជាប្រាក់រៀលខ្មែរ និងរយៈពេលកម្ចីរហូតដល់ ៧២ខែ។



បន្ទាប់ពីប្រើប្រាស់សេវាកម្មរបស់ប៊ីអេនខេស៊ី ខ្ញុំមានអារម្មណ៍ថាសេដ្ឋកិច្ចគ្រួសាររបស់ខ្ញុំកាន់តែប្រសើរឡើង ការចាយវាយក៏ស្រួលជាងមុន ដោយសារខ្ញុំមានខ្ទង់ចំណាយត្រឹមត្រូវ។ បន្ទាប់មានមន្ត្រីឥណទានលើកទឹកចិត្តអោយខ្ញុំខិតខំប្រឹងប្រែងរកស៊ី និងបង់ប្រាក់អោយបានទៀងទាត់ដើម្បីងាយស្រួលខ្ចីវគ្គក្រោយទៀត ពីព្រោះវគ្គក្រោយត្រូវពង្រីកមុខរបរបន្ថែមទៀត។ ( **សាក់ រស្មី / សាខាស្រុកអង្គស្នួល** )



ខ្ញុំមានគោលបំណងចង់ទិញដីមួយកន្លែងសម្រាប់ជាទ្រព្យចំពោះកូនៗ។ ដូចនេះខ្ញុំបានស្វែងរកសេវាកម្មឥណទាន ហើយអ្នកជិតខាងគាត់បានណែនាំខ្ញុំពីផលិតផលកម្ចីនៅប៊ីអេនខេស៊ី ថាលោកគ្រូបំរើសេវាកម្មលឿន រហ័ស និងមានទំនុកចិត្តក្នុងការប្រើប្រាស់ប្រាក់កម្ចី មានភាពងាយស្រួលក្នុងការបង់សងប្រាក់ប្រចាំខែ។ ម្យ៉ាងវិញទៀតអត្រាការប្រាក់ក៏សមរម្យផងដែរ ទើបធ្វើអោយខ្ញុំសម្រេចចិត្តទទួលប្រាក់កម្ចីពីប៊ីអេនខេស៊ី ។ ខ្ញុំសប្បាយចិត្តយ៉ាងខ្លាំងដែលបានទិញដីមួយកន្លែងដែលជាទ្រព្យសម្រាប់កូនៗរបស់ខ្ញុំនៅពេលអនាគត។ តាមរយៈកម្ចីរបស់ប៊ីអេនខេស៊ី ខ្ញុំបានសម្រេចគោលបំណង់មួយដែលខ្ញុំចង់ធ្វើចំពោះកូនៗ។ ( **គួន ផាន់ណោត / សាខាស្រុកសំរោង** )

# កម្មវិធីទូរស័ព្ទដៃ«BNKC Mobile App»




## កម្មវិធីទូរស័ព្ទដៃ «BNKC MFI Mobile App»

### មុខងារ

ប្រឹក្សាប្រាក់កម្ចី

ស្នើសុំប្រាក់កម្ចី

តាមដានកាលវិភាគសងប្រាក់កម្ចី

សងប្រាក់កម្ចីតាមរយៈភ្នាក់ងាររ៉ឹង

### សេចក្តីណែនាំ



កម្មវិធីទូរស័ព្ទចល័ត «BNKC MFI» ដែលត្រូវបានដាក់ឱ្យដំណើរការក្នុងខែមិថុនា ឆ្នាំ២០២១ គឺជាការបង្ហាញពីប្រសិទ្ធភាពនៃការច្នៃប្រឌិតឌីជីថលដែលផ្តោតលើតម្រូវការរបស់អ្នកប្រើប្រាស់។ វាជាជំហានដំបូងក្នុងការផ្លាស់ប្តូរផ្នត់គំនិតដើម្បីប្រែក្លាយវិបត្តិទៅជាឱកាសមួយចាប់តាំងពីឆ្នាំ២០១៩ ដែលអំឡុងពេលនោះមិនត្រឹមតែប្រទេសកម្ពុជាប៉ុណ្ណោះទេ ពិភពលោកទាំងមូលបាននិងកំពុងមានភាពភ័យខ្លាចដោយសារតែការ ផ្ទុះឡើងនៃមេរោគកូរ៉ូណា។

BNKC MFI Mobile App ជាកម្មវិធីទូរស័ព្ទដៃរបស់ MFI ដំបូងគេដែលត្រូវបានដាក់អោយដំណើរការនៅក្នុងប្រទេសកម្ពុជា ដែលអាចកំណត់នូវតម្រូវការរបស់អតិថិជន ហើយមុខងារ និង ការរចនាមានលក្ខណៈសាមញ្ញសមស្រប និងងាយស្រួលសម្រាប់អតិថិជនទាំងពីរភេទ ក្នុងការចូលទៅប្រើប្រាស់។ លើសពីនេះទៅទៀត ជាមួយនឹងមុខងារដូចជា ការប្រឹក្សាប្រាក់កម្ចី ការស្នើសុំប្រាក់កម្ចី កាលវិភាគសងប្រាក់កម្ចី និងការសងប្រាក់កម្ចីតាមរយៈភ្នាក់ងាររ៉ឹង ជួយអោយជីវិតហិរញ្ញវត្ថុកាន់តែឆ្លាតវៃ។

គិតត្រឹមខែធ្នូ ឆ្នាំ២០២២ អតិថិជនប្រហែល ៧,៩៧៨នាក់បានទាញយកកម្មវិធី BNKC Mobile App។ ការប្រឹក្សាប្រាក់កម្ចី និងការស្នើសុំកម្ចីត្រូវធ្វើឡើងយ៉ាងសកម្មនៅលើកម្មវិធីនេះ។ ប៊ីអេនខេស៊ី នឹងបន្តផ្តល់នូវភាពច្នៃប្រឌិតឌីជីថលផ្នែកហិរញ្ញវត្ថុដោយឆ្លុះបញ្ចាំងពីតម្រូវការរបស់អតិថិជន ដើម្បីជីវិតហិរញ្ញវត្ថុដ៏ឆ្លាតវៃរបស់អតិថិជននាពេលអនាគត ។

# ក្រុមការងាររបស់យើង

# រចនាសម្ព័ន្ធគ្រឹះស្ថាន



# គណៈគ្រប់គ្រងកំពូល



**លោក KIM SOONJO អគ្គនាយកប្រតិបត្តិ**

លោក Kim Soonjo បានចាប់ផ្តើមបម្រើការងារនៅគ្រឹះស្ថាននៅដើមខែតុលា ឆ្នាំ២០២០ ក្នុងមុខដំណែងជាអគ្គនាយកប្រតិបត្តិ។ លោកមានបទពិសោធន៍បម្រើការងារនៅក្នុង ប៊ីអេនខេស៊ី មីយ៉ាន់ម៉ារ យៈពេល៦ឆ្នាំ ក្នុងមុខដំណែងជាអគ្គនាយកប្រតិបត្តិ។ មុនចូលបម្រើការងារក្នុង ប៊ីអេនខេស៊ី មីយ៉ាន់ម៉ា លោកជានាយកគ្រប់គ្រងសាខា Daejeon របស់ក្រុមហ៊ុន BNK Capital រយៈពេល៤ឆ្នាំ ហើយក៏ធ្លាប់បម្រើការងារនៅក្នុងក្រុមហ៊ុន Aju Capital រយៈពេល ៦ឆ្នាំក្នុងមុខដំណែងដូចជា ប្រធានផ្នែកលក់ ប្រធានគ្រប់គ្រងឥណទានជាដើម។ លោកមានបទពិសោធន៍ និងជំនាញក្នុងវិស័យហិរញ្ញវត្ថុនេះជាង ១៥ ឆ្នាំហើយ។

---



**លោក LEE SIHYUN អគ្គនាយករង**

លោក LEE Sihyun បានចាប់ផ្តើមការងារនៅគ្រឹះស្ថាន នៅខែកក្កដា ឆ្នាំ២០១៩។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រវិស្វកម្មប៉ូលីមែរនៅសាកលវិទ្យាល័យជាតិភុក្យុង នៃសាធារណរដ្ឋកូរ៉េ នៅឆ្នាំ ១៩៩៨។ លោកមានបទពិសោធន៍ជាច្រើនឆ្នាំទាក់ទងនឹងវិស័យហិរញ្ញវត្ថុនៅសាធារណរដ្ឋកូរ៉េ។ លោកបានបម្រើការងារនៅធនាគារ Busan Parangsae Saving Bank អស់រយៈពេល៤ឆ្នាំ ក្នុងតួនាទីជាប្រធានគ្រប់គ្រងឥណទាន។ លោកបានចូលបម្រើការងារនៅ BNK Capital ក្នុងខែតុលា ២០១១ យោងទៅលើលទ្ធផលការងារដ៏ឆ្នើមជាច្រើនរបស់លោកនៅ BNK Capital លោកត្រូវបានតែងតាំងអោយកាន់តំណែងក្នុងផ្នែកគ្រប់គ្រងជាច្រើនបន្តបន្ទាប់គ្នាដូចជា គ្រប់គ្រងប្រឹក្សាយោបល់អតិថិជន គ្រប់គ្រងគម្រោងឥណទាន គ្រប់គ្រងត្រួតពិនិត្យឥណទាន និង គ្រប់គ្រងផ្នែកគ្រប់គ្រងហានិភ័យ។

---



**លោក PARK Hyungmo ប្រធាននាយកព័ត៌មានវិទ្យា**

លោក PARK Hyungmo បានចូលបម្រើការងារក្នុងគ្រឹះស្ថាន នៅខែឧសភា ឆ្នាំ២០២២ ក្នុងមុខដំណែងជាប្រធាននាយកព័ត៌មានវិទ្យា។ លោកបញ្ចប់ការសិក្សាកំរិតបរិញ្ញាបត្រ ផ្នែកវិទ្យាសាស្ត្រនិងវិស្វកម្មកុំព្យូទ័រពីសាកលវិទ្យាល័យជាតិ Pusan នៃសាធារណរដ្ឋកូរ៉េ។ លោកបានចាប់ផ្តើមអាជីពការងារនៅ BNK Capital នៅឆ្នាំ ២០១២ ក្នុងមុខដំណែងជាមន្ត្រីផ្នែកព័ត៌មាន។ កំឡុងពេល១០ឆ្នាំ គាត់បានចូលរួមគម្រោងផែនការការងារជាច្រើន ដូចជាគម្រោងអភិវឌ្ឍន៍កម្មវិធីទូរស័ព្ទដៃ គម្រោងអភិវឌ្ឍន៍ប្រព័ន្ធធនាគារ ជាដើម។ លោក Hyungmo ក៏ធ្លាប់ជាចូលរួមក្នុងគម្រោងសាជីវកម្មគ្រប់គ្រងដោយ SAMSUNG នៅវេទិកាហិរញ្ញវត្ថុអន្តរជាតិ Pusan នៅសាធារណរដ្ឋកូរ៉េ។ លោកមានជំនាញជាច្រើន ដូចជា Java, PHP, Java Script, C, C++, HTML, XML និង Oracle ។ល។

# គណៈគ្រប់គ្រង





**កញ្ញា ពៅ សាទ្បឹម ប្រធាននាយកដ្ឋានផែនការ**

កញ្ញា ពៅ សាទ្បឹម មានមុខតំណែងជាប្រធាននាយកដ្ឋានផែនការនៅក្នុងគ្រឹះស្ថាន។ កញ្ញាបានចូលបម្រើការងារនៅគ្រឹះស្ថាន នៅខែមករា ឆ្នាំ២០១៦ ជាជំនួយការអគ្គនាយកប្រតិបត្តិ។ កញ្ញាក៏ធ្លាប់ជាចូលរួមក្នុងគម្រោងសិក្សារស្រាវជ្រាវ និងវិភាគជាច្រើនលើផ្នែកអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចនៅសាកវិទ្យាល័យនៅសាធារណរដ្ឋកូរ៉េមុនត្រឡប់មកប្រទេសកម្ពុជាវិញ។

កញ្ញា ពៅ សាទ្បឹមបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញរដ្ឋបាលសាធារណៈ នៅឆ្នាំ២០១៤ និងបានបញ្ចប់ថ្នាក់បរិញ្ញាបត្រចំនួនពីរ ផ្នែកសេដ្ឋកិច្ច និងផ្នែករដ្ឋបាលសាធារណៈនៅសាកលវិទ្យាល័យស្ត្រី Ewha នៅសាធារណរដ្ឋប្រទេសកូរ៉េ នៅឆ្នាំ២០១១។

---

**លោក អ៊ុន រតនៈ  ប្រធាន នាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល**

លោក អ៊ុន រតនៈ មានមុខតំណែងជាប្រធាននាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល។ លោកបានចូលបម្រើការងារនៅគ្រឹះស្ថាន នៅខែមិថុនា ឆ្នាំ២០១៦។ មុនការចាប់អាជីពនៅគ្រឹះស្ថានប៊ីអេនខេស៊ី លោកធ្លាប់ធ្វើជាប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងជាជំនួយការប្រធានគម្រោងនៅក្រុមហ៊ុនសាងសង់អស់រយៈពេល ៣ឆ្នាំ។ លោកក៏ធ្លាប់ជានាយកគ្រប់គ្រងសាលារៀន នៃអង្គការ ICMS Mission Society ដែលមានមូលដ្ឋាននៅប្រទេសថៃរយៈពេល១ឆ្នាំ។



លោក អ៊ុន រតនៈ បានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញគ្រប់គ្រងធុរៈកិច្ចពីសកលវិទ្យាល័យ បៀលប្រាយ នៅក្នុងខែមីនា ឆ្នាំ២០១៥។ ក្នុងឆ្នាំ២០១២ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រចំនួនពីរក្នុងពេលតែមួយផងដែរ គឺទីមួយផ្នែកអន្តរវប្បធម៌ និងទីពីរផ្នែកអក្សរសាស្ត្រភាសាអង់គ្លេសពីសាកលវិទ្យាល័យ KOSIN  នៅទីក្រុងប៊ូសាន សាធារណរដ្ឋកូរ៉េ។ ក្រៅពីនេះលោកបានសិក្សាវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសវិជ្ជាជីវៈស្តីពីអ្នកជំនាញគ្រប់គ្រងធនធានមនុស្ស, ការប្រកាសអាករលើតម្លៃបន្ថែមតាមវិធីគិតអាករជំនួស (Reverse Charge) និងការប្រើប្រាស់សេវាកម្មអេឡិចត្រូនិកពន្ធដារ, អ្នកជំនាញគ្រប់គ្រងគំរោង, ដំណើរការគ្រប់គ្រងលទ្ធផលការងារប្រកបដោយប្រសិទ្ធិភាព, គោលការណ៍និងអត្ថប្រយោជន៍សមាជិកបសស លើប្រាក់សោធនិវត្តន៍, គ្រប់គ្រងការទូទាត់ប្រាក់ឈ្នួល និងទូទាត់ពន្ធដារកម្ពុជា, ការគិតអត្ថប្រយោជន៍បុគ្គលិកក្នុងវិស្ស័យធនាគារនិងហិរញ្ញវត្ថុ, យុទ្ធសាស្ត្ររើស រៀបនិងរក្សាបុគ្គលិក, ធនធានមនុស្សនិងការប្រតិបត្តតាមក្នុងវិស័យហិរញ្ញវត្ថុ, ការគ្រប់គ្រងធនធានមនុស្សសម្រាប់អ្នកគ្រប់គ្រងជួរមុខ, ច្បាប់ស្តីពីការងារនិងការប្រតិបត្តតាមច្បាប់, ការសរសេរគោលនយោបាយ និងគោលការណ៍គ្រប់គ្រង់ធនធានមនុស្ស, ការគ្រប់គ្រងលទ្ធផលការងារនិយោជិក និងភាពជាអ្នកដឹកនាំ, ការគ្រប់គ្រងរដ្ឋបាល និងគ្រប់គ្រងការិយាល័យ ។ល។

---

**លោក ផេង ភ័ក្ត្រ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ**

លោក ផេង ភ័ក្ត្រ បានចូលបម្រើការងារនៅ គ្រឹះស្ថាន ក្នុងខែសីហា ឆ្នាំ២០១៩ មុខតំណែងជា ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ។ លោកមានបទពិសោធន៍ការងារក្នុងវិស័យមីក្រូហិរញ្ញវត្ថុរយៈពេលលើស១៥ឆ្នាំ។ មុនចាប់អាជីពការងារជាមួយ គ្រឹះស្ថាន ប៊ីអេនខេស៊ី លោកធ្លាប់ធ្វើការនៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និងក្រុមហ៊ុនអន្តរជាតិ ក្នុងមុខតំណែងជាច្រើនដូចជា សវនករផ្ទៃក្នុង គណនេយ្យករជាន់ខ្ពស់ គណនេយ្យករគ្រប់គ្រងជាន់ខ្ពស់ ប្រធានត្រួតពិនិត្យហិរញ្ញវត្ថុ ប្រធានវិភាគអាជីវកម្ម ប្រធានរៀបចំផែនការថវិកា ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងរដ្ឋបាល ហើយលោកក៏មានបទពិសោធក្នុងការប្តូរប្រព័ន្ធធនាគារស្នូល ការធ្វើឲ្យកាន់តែប្រសើរនូវប្រព័ន្ធការងារ និងជាគ្រូបង្រៀននៅសាកលវិទ្យាល័យ រយៈពេលប្រាំមួយឆ្នាំ មុខវិជ្ជា គណនេយ្យ និងសវនកម្ម ផងដែរ ។



លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញគ្រប់គ្រងហិរញ្ញវត្ថុ ពីសកលវិទ្យាល័យ នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅក្នុងឆ្នាំ២០១១ និងបញ្ចប់ថ្នាក់បរិញ្ញាបត្រ ហិរញ្ញវត្ថុ និងគណនេយ្យ ព្រមទាំងថ្នាក់បរិញ្ញាបត្រអក្សរសាស្ត្រភាសាអង់គ្លេស ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង សាកលវិទ្យាល័យន័រតុន និងកំពុងបន្តការសិក្សាជំនាញគណនេយ្យករអាជីព។ ក្រៅពីនេះលោកបានសិក្សាវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសវិជ្ជាជីវៈ ស្តីពីការវិភាគសូចនាករប្រតិបត្តិហិរញ្ញវត្ថុ ការគ្រប់គ្រងទ្រព្យសកម្ម និងបំណុល ការគ្រប់គ្រងហានិភ័យរបាយការណ៍តុល្យការ ការបង្ហាញហានិភ័យឥណទាន ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិកម្ពុជា និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម ប្រព័ន្ធពន្ធដារកម្ពុជា ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ការគ្រប់គ្រងហានិភ័យ កម្មវិធីអភិវឌ្ឍអ្នកគ្រប់គ្រង ភាពជាអ្នកដឹកនាំ និងការលើកទឹកចិត្ត ។ល។



**លោក ពៅ ច័ន្ទមិថុនា  ប្រធាននាយកដ្ឋានវិភាគឥណទាន**

លោក ពៅ ច័ន្ទមិថុនា មានមុខតំណែងជាប្រធាននាយកដ្ឋានវិភាគឥណទាន។ លោកបានចូលបម្រើការងារក្នុងគ្រឹះស្ថាន នៅខែមិថុនា ឆ្នាំ២០២០។ មុនលោកចាប់អាជីពនៅគ្រឹះស្ថាន ប៊ីអេនខេស៊ី លោកធ្លាប់បម្រើការងារនៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុជាច្រើនមុខតំណែងដូចជា ប្រធានគ្រប់គ្រងប្រាក់កម្ចី ប្រធានភ្នាក់ងារឥណទាននៅតាមបណ្តាធនាគារដ៏ឈានមុខមួយចំនួននៅប្រទេសកម្ពុជា។ លោកមានបទពិសោធន៍ និងចំណេះដឹងខាងវិស័យហិរញ្ញវត្ថុអស់រយៈពេលជាង ១0ឆ្នាំ។

លោក ពៅ ច័ន្ទមិថុនាបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញគ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង នៅក្នុងខែសីហា ឆ្នាំ២០១៥។ នៅក្នុងឆ្នាំ២០០៩ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញធនាគារ និងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង។ នៅឆ្នាំ២០០៦ លោកបានបញ្ចប់ថ្នាក់ប្រកាសនីយបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងធនាគារ នៅមណ្ឌលសិក្សាបច្ចេកទេសធនាគារ។

---

**លោក ស៊ិន សុខនាង  ប្រធាននាយកដ្ឋានឥណទាន**

លោក ស៊ិន សុខនាងបានចាប់ផ្តើមចូលបម្រើការងារនៅគ្រឹះស្ថាន នៅក្នុងខែធ្នូ ឆ្នាំ២០២២។ លោកមានបទពិសោធន៍ជាង១៥ឆ្នាំក្នុងវិស័យមីក្រូហិរញ្ញវត្ថុ។ លោកធ្លាប់ជាមន្រ្តីឥណទាន មន្រ្តីឥណទានជាន់ខ្ពស់ ប្រធានតំបន់ នាយកសាខា នាយកភូមិភាគ និងនាយករងនាយកដ្ឋានគ្រប់គ្រងសាខាជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដ៏ធំមួយនៅក្នុងប្រទេសកម្ពុជា។

លោក ស៊ិន សុខនាងបានបញ្ចប់អនុបណ្ឌិតផ្នែកហិរញ្ញវត្ថុនៅសាកលវិទ្យាល័យជាតិគ្រប់គ្រងនៅឆ្នាំ ២០១២ និងបរិញ្ញាបត្រកសិកម្ម នៅសាកលវិទ្យាល័យវេទមហាឫស្សី ខេត្តព្រៃវែងនៅឆ្នាំ២០០៤។ លោកក៏បានចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗទៀតដូចជា ការអភិវឌ្ឍន៍ខ្លួនជាអ្នកដឹកនាំ គ្រូបង្គោល ការការពារ និងគ្រប់គ្រងឥណទានយឺតយ៉ាវ និងការនិយាយជាសាធារណៈជាដើម។



---



**កញ្ញា សៀ ណៃឡេង  ប្រធាននាយកដ្ឋានគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម**

កញ្ញា សៀ ណៃឡេង មានមុខដំណែងជាប្រធាននាយកដ្ឋានគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម។ កញ្ញាបានចូលបម្រើការងារនៅគ្រឹះស្ថាន នៅខែមករា ឆ្នាំ២០១៩។ មុនពេលចាប់ផ្តើមអាជីពនៅគ្រឹះស្ថាន កញ្ញាធ្លាប់បម្រើការងារជាជំនួយការមេធាវី និងជាមន្ត្រីប្រតិបត្តិតាមនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយ។ កញ្ញាក៏ធ្លាប់ជាអ្នកប្រឹក្សាផ្នែកច្បាប់ ស្រាវជ្រាវផ្នែកច្បាប់។ កញ្ញាត្រូវបានទទួលស្គាល់ជាផ្លូវការពីធនាគារជាតិនៃកម្ពុជា និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាក្នុងមុខងារជាមន្ត្រីប្រតិបត្តិតាម។

កញ្ញា សៀ ណៃឡេង បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្រ្ត ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសេដ្ឋកិច្ច ក្នុងឆ្នាំ២០១៧ និងបានបញ្ចប់ថ្នាក់ភាសាអង់គ្លេសទូទៅពីសាកលវិទ្យាល័យបញ្ញាស្រ្តកម្ពុជាផងដែរ។ ក្រៅពីនេះ កញ្ញាបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញ Regulatory Compliance និង Anti-Money Laundering នៅវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ ព្រមទាំងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា -ល- ។

**លោក អ៊ុម សុបុត្រា  ប្រធាននាយកដ្ឋានដោះស្រាយបំណុល**



លោក អ៊ុម សុបុត្រា មានមុខតំណែងជាប្រធាននាយកដ្ឋានដោះស្រាយបំណុល។ លោកបានចូលបំរើការងារនៅគ្រឹះស្ថាន នៅខែសីហា ឆ្នាំ២០១៥ ដែលជាឆ្នាំបង្កើតគ្រឹះស្ថាន។ លោកមានបទពិសោធន៍ការងារក្នុងវិស័យគ្រឹះស្ថានហិរញ្ញវត្ថុ រយៈពេលជាង១១ឆ្នាំ ។ មុនចាប់អាជីពការងារជាមួយគ្រឹះស្ថាន លោកធ្លាប់បម្រើការងារនៅ នៅធានាគារ អេស៊ីលីដា ភីអិលស៊ី អស់រយៈពេលជាង ១១ ឆ្នាំ មានមុខងារជាមន្ត្រីឥណទាន និងជាសវនករផ្ទៃក្នុងជាង១ឆ្នាំ ។

លោក អ៊ុម សុបុត្រា បានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឯកទេសផ្នែកហិរញ្ញវត្ថុ ពីសកលវិទ្យាល័យជាតិគ្រប់គ្រង នៅក្នុងឆ្នាំ២០១៨ និងបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាញគ្រប់គ្រងក្នុងឆ្នាំ២០០៣ នៅវិទ្យាស្ថានជាតិគ្រប់គ្រង ។ លោកក៏បានចូលរួមវគ្គបណ្តុះបណ្តាលមួយចំនួនដូចជា ការរៀបចំបណ្តឹង វិភាគប្រតិបត្តិការគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ការគ្រប់គ្រងហានិភ័យ និងភាពជោគជ័យនៃការលក់ រួមទាំងសិទ្ធិមនុស្ស ជាដើម ។ល។

---

**លោកអាន សុខខាក់  ប្រធាននាយកដ្ឋានព័ត៌មានវិទ្យា**



លោក អាន សុខខាក់ បានចូលបម្រើការងារនៅគ្រឹះស្ថាន នៅខែមេសា ឆ្នាំ២០១៥។ មុនចូលបម្រើការនៅគ្រឹះស្ថាន លោកធ្លាប់ជាមន្ត្រីគ្រប់គ្រង Database នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយរយៈពេល ២ឆ្នាំ និងជាអ្នកអភិវឌ្ឍន៍កម្មវិធីកុំព្យូទ័រក្នុងក្រុមហ៊ុនមួយ រយៈពេល២ឆ្នាំ។ លោកក៏ធ្លាប់ជាបុគ្គលិកផ្នែកសម្របសម្រួលព័ត៌មានវិទ្យានៅសាលាអន្តរជាតិមួយ រយៈពេល១ឆ្នាំ និងជាគ្រូបង្រៀនអភិវឌ្ឍន៍កម្មវិធីកុំព្យូទ័រផងដែរ។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជំនាញវិស្វកម្ម និងបច្ចេកទេសកុំព្យូទ័រ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្នុងឆ្នាំ២០០៩។ លោកបានចូលរួមវគ្គបណ្តុះបណ្តាល ជំនាញបច្ចេកវិទ្យាជាច្រើនផ្នែកដូចជា C-Programming, C++, Java, C#, VB.net, PHP, MySQL, SQL Server, Database Management System និង IT Project Management។

---

**លោក រឿន រិទ្ធា  ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង**



លោក រឿន រិទ្ធា បានចូលបម្រើការងារនៅគ្រឹះស្ថាននៅខែឧសភា ឆ្នាំ២០១៩ ។ លោកចាប់ផ្តើមអាជីពជាសវនករផ្ទៃក្នុង នៅវិស័យធនាគារ និងហិរញ្ញវត្ថុអស់រយៈពេលជាង ១៣ឆ្នាំ ។ មុនបម្រើការងារនៅគ្រឹះស្ថាន លោកធ្លាប់ជាសវនករផ្ទៃក្នុងនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុសីលានិធិរយៈពេល ៤ឆ្នាំ និងសវនករផ្ទៃក្នុងជាន់ខ្ពស់នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី រយៈពេល៥ឆ្នាំ ។

លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ នៅសាកលវិទ្យាល័យន័រតុន ក្នុងឆ្នាំ ២០០៩ និងកំពុងបន្តការសិក្សាថ្នាក់អនុបណ្ឌិត ជំនាញនីតិឯកជន នៅពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា ។ ដើម្បីបំពេញបន្ថែមនូវចំណេះដឹងផ្នែកសវនកម្ម លោកបានចូលរួមវគ្គសិក្សាខ្លីជាច្រើនដូចជា ការត្រួតពិនិត្យផ្ទៃក្នុង និងការការពារហានិភ័យនៃការក្លែងបន្លំ ច្បាប់ពន្ធដារកម្ពុជា ការគ្រប់គ្រងសវនកម្មផ្ទៃក្នុង ច្បាប់កិច្ចសន្យា និងកិច្ចព្រមព្រៀងប្រាក់កម្ចីក្នុងប្រតិបត្តិការហិរញ្ញវត្ថុ និងមូលដ្ឋានគ្រឹះនៃសវនកម្មផ្ទៃក្នុង និងទទួលបានវិញ្ញាបនបត្រថ្នាក់សវនកម្មជាន់ខ្ពស់ទទួលស្គាល់ពី IFC នៅវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ ។

# ការអភិវឌ្ឍសមត្ថភាពបុគ្គលិក

## ការបណ្តុះបណ្តាលផ្ទៃក្នុង

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេនខេស៊ី (ខេមបូឌា) ភីអិលស៊ី តែងតែធ្វើការបណ្តុះបណ្តាលផ្ទៃក្នុងទៅដល់បុគ្គលិកទាំងអស់ជានិច្ចជាកាល។ ការបណ្តុះបណ្តាលនេះ មិនត្រឹមតែធ្វើឡើងក្នុងគោលបំណងអោយបុគ្គលិកទទួលបានការយល់ដឹងកាន់តែច្បាស់អំពីការងារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបណ្តុះនូវការប្រកាន់យកផ្នត់គំនិត និងក្រមសីលធម៌ការងារប្រកបដោយវិជ្ជាជីវៈ។ ការបណ្តុះបណ្តាលផ្ទៃក្នុងត្រូវបានធ្វើឡើងដោយបុគ្គលិកថ្នាក់គ្រប់គ្រង បុគ្គលិកដែលមានសមត្ថភាពខ្ពស់ ឬ បុគ្គលិកដែលមានជំនាញវិជ្ជាជីវៈនៅក្នុងគ្រឹះស្ថាន ដើម្បីយល់ដឹង និងអនុវត្តអោយបានត្រឹមត្រូវនូវគោលនយោបាយ និងគោលការណ៍ណែនាំរបស់គ្រឹះស្ថាន។



ទទួលស្វាគមន៍អ្នកចូលរួម







ចូលរួមវគ្គបណ្តុះបណ្តាល



ថតរូបអនុស្សាវរីយ៍បន្ទាប់ពីការហ្វឹកហាត់បញ្ចប់យ៉ាងជោគជ័យ

# វគ្គបណ្តុះបណ្តាលខាងក្រៅ

ក្រៅពីការបណ្តុះបណ្តាលផ្ទៃក្នុង គ្រឹះស្ថានក៏បានបញ្ជូនបុគ្គលិករបស់ខ្លួនអោយចូលរួមការបណ្តុះបណ្តាលខាងក្រៅ និងសិក្ខាសាលាដែលរៀបចំឡើងដោយធនាគារជាតិនៃកម្ពុជា សមាគមន៍គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៃកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ ការិយាល័យឥណទានកម្ពុជា(CBC) និងក្រសួងពាក់ព័ន្ធផ្សេងទៀតដូចជា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងពាណិជ្ជកម្មជាដើម។

ការបណ្តុះបណ្តាលខាងក្រៅគ្រឹះស្ថានធ្វើឡើងក្នុងគោលបំណងពង្រឹងសមត្ថិភាពរបស់បុគ្គលិកអោយមាន វិជ្ជាជីវៈខ្ពស់ និងធ្វើអោយប្រតិបត្តិការរបស់គ្រឹះស្ថានអនុលោមតាមច្បាប់ពាណិជ្ជកម្ម ស្តង់ដារគណនេយ្យអន្តរជាតិ ជាពិសេសបញ្ញត្តិ និងសេចក្តីប្រកាសទាំងឡាយដែលចេញដោយធនាគារជាតិនៃកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ។

| នាយកដ្ឋាន | ប្រធានបទ |
|---|---|
| សវនកម្មផ្ទៃក្នុង | ការអនុវត្តពន្ធប្រចាំឆ្នាំ និងពន្ធលើប្រាក់ចំណូល ក្នុងស្ថាប័នហិរញ្ញវត្ថុ |
| សវនកម្មផ្ទៃក្នុង | ច្បាប់កិច្ចសន្យា និងកិច្ចសន្យាខ្ចីប្រាក់សម្រាប់ប្រតិបត្តិការហិរញ្ញវត្ថុ |
| សវនកម្មផ្ទៃក្នុង | ការជ្រើសរើសប៉ាន់គម្រូសវនកម្ម |
| ឥណទាន | ការគ្រប់គ្រងសាខាប្រកបដោយប្រសិទ្ធភាពសម្រាប់ប្រធានសាខា |
| ឥណទាន | ការពង្រឹងសមត្ថភាពគ្រប់គ្រងសាខា ប្រកបដោយប្រសិទ្ធភាព ចីរភាព ក្រមសីលធម៌ និងវិជ្ជាជីវៈ |
| ឥណទាន | សន្និសិទមីក្រូហិរញ្ញវត្ថុប្រចាំឆ្នាំ២០២២ |
| គ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម | មុខងារគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម |








ចូលរួមកម្មវិធីប្រគល់វិញ្ញាបនប័ត្រ

# កម្មវិធី HAPPY SHARING

កម្មវិធី Happy Sharing បានបង្កើតឡើងក្នុងគោលបំណងចែករំលែកនូវសេចក្តីស្រលាញ់ និងចូលរួមចំណែកក្នុងសង្គម ដោយមិនប្រកាន់អាយុ ឬសញ្ជាតិ។ យើងបានឃើញនូវស្ថានភាពថ្នាក់រៀន និងសាលាតាមបណ្តាញសង្គម ហើយឃើញសកម្មភាពកុមារតូចៗដែលកំពុងបន្តការសិក្សារបស់ពួកគេក្នុងស្ថានភាពលំបាក រូបភាពទាំងនេះបានជំរុញទឹកចិត្តអោយយើងបង្កើតកម្មវិធីនេះឡើង។

ទោះបីជាសម្ភារៈដែលពួកយើងនាំយកមកនេះជាអំណោយបន្តិចបន្តួច តែយើងសង្ឃឹមថា វានឹងជួយរួមចំណែកមួយផ្នែកដល់តម្រូវការរបស់សិស្សានុសិស្ស និងបងប្អូនប្រជាពលរដ្ឋ។ យើងជាបុគ្គលិកទាំងអស់គ្នាសូមជូនពរ ដល់អ្នកចូលរួមគ្រប់ៗរូប សូមមានសុភមង្គល និងភាពរីករាយ ដូចឈ្មោះរបស់កម្មវិធី Happy Sharing។








បុគ្គលិក BNKC ក្នុងកម្មវិធី Happy Sharing (១៥ កញ្ញា ២០២២) នៅសាលាបឋមសិក្សាត្បែងរាំ

# សិក្ខាសាលាថ្នាក់គ្រប់គ្រង



សិក្ខាសាលាថ្នាក់គ្រប់គ្រងប្រចាំឆ្នាំ២០២២





## សិក្ខាសាលាថ្នាក់គ្រប់គ្រង ប្រចាំឆ្នាំ២០២២

កាលពីថ្ងៃទី១៣-១៤ ខែសីហាកន្លងទៅនេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ BNKC (Cambodia) MFI Plc. បានរៀបចំសិក្ខាសាលាថ្នាក់គ្រប់គ្រងមួយ (Management Workshop) ដែលធ្វើឡើងនៅរមណីយដ្ឋាន គិរីរម្យ ក្នុងគោលបំណងផ្តល់ឱកាសអោយគណៈគ្រប់គ្រងទាំងអស់បានជួបជុំពិភាក្សា ចែករំលែកបទពិសោធន៍ ក៏ដូចជាជជែកវែកញែកអំពីយុទ្ធសាស្រ្តសម្រាប់ឆមាសទី២ នៃឆ្នាំ២០២២ និងបង្កើតសកម្មភាពពង្រឹងស្មារតីក្រុមផងដែរ។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ BNKC (Cambodia) MFI Plc. តែងតែខិតខំព្យាយាមបង្កើនទំនាក់ទំនងការងារក្នុងថ្នាក់គ្រប់គ្រង ចែករំលែកចំណេះដឹង និងអភិវឌ្ឍន៍សមត្ថភាព ក៏ដូចជាផ្តល់នូវបរិយាកាសការងារល្អៗជូនទៅដល់បុគ្គលិកទាំងអស់។

ពួកយើងជឿថា ការផ្លាស់ប្តូរយោបល់ ការចែករំលែកបទពិសោធន៍ និងការជជែកវែករកគន្លឹះល្អៗផ្តល់អោយគ្នាទៅវិញទៅមក ក្នុងថ្នាក់គ្រប់គ្រងអាចជំរុញអោយមានលិទ្ធិផលវិជ្ជមានកាន់តែច្រើនក្នុងប្រតិបត្តិការការងារទាំងមូល។

BNK Financial Group

# របាយការណ៍សវនកម្មឯករាជ្យ


៣៤ របាយការណ៍សវនកម្មឯករាជ្យ

**របាយការណ៍ហិរញ្ញវត្ថុ**

៣៧ របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

៣៨ របាយការណ៍លទ្ធផលពេញលេញ

៣៩ របាយការណ៍បម្រែបម្រួលមូលធន

៤០ របាយការណ៍លំហូរសាច់ប្រាក់

# របាយការណ៍របស់សវនករឯករាជ្យ

ជូនចំពោះ៖ ភាគហ៊ុនិករបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេនខេស៊ី (ខេមបូឌា) ភីអិលស៊ី

## មតិយោបល់

យើងខ្ញុំ បានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេនខេស៊ី (ខេមបូឌា) ភីអិលស៊ី ហៅកាត់ថា ("ក្រុមហ៊ុន") ដែលរួមមាន របាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ របាយការណ៍លទ្ធផលពេញលេញ របាយការណ៍បម្រែបម្រួលមូលធន របាយការណ៍លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ និងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ រួមទាំងសេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ ។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និងស្ថានភាពលំហូរសាច់ប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទបញ្ចប់ ដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម ("CIFRS for SMEs")។

## មូលដ្ឋាននៃមតិយោបល់

យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិរបស់កម្ពុជា ("CISAs")។ ការទទួលខុសត្រូវរបស់យើងខ្ញុំ ក្រោមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុងផ្នែកនៃការទទួលខុសត្រូវរបស់សវនករចំពោះសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ នៃរបាយការណ៍របស់យើងខ្ញុំ។យើងខ្ញុំមានឯករាជ្យភាពពីក្រុមហ៊ុន ដោយយោងទៅលើក្រមសីលធម៌សម្រាប់វិជ្ជាជីវៈរបស់គណនេយ្យករជំនាញ និងសវនករប្រតិស្រុត ដែលចេញដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនៃកម្ពុជា រួមជាមួយនឹងតម្រូវការខាងសីលធម៌ ដែលពាក់ព័ន្ធទៅនឹងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា ហើយយើងខ្ញុំក៏បានបំពេញនូវទំនួលខុសត្រូវដទៃទៀតតាមតម្រូវការទាំងនេះផងដែរ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្របដើម្បីផ្តល់ជាមូលដ្ឋានក្នុងការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។

## បញ្ហាផ្សេងៗ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ត្រូវបានធ្វើ សវនកម្មដោយសវនករផ្សេងទៀត ដែលបានបញ្ចេញមតិយោបល់គ្មានបញ្ហាលើរបាយការណ៍ទាំងនោះ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២។

## ព័ត៌មានផ្សេងៗ

ព័ត៌មានផ្សេងៗ ដែលបានទទួលនាកាលបរិច្ឆេទនៃរបាយការណ៍របស់សវនករ រួមមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលចាប់ពីទំព័រ ទី១ ដល់ទំព័រទី៥។ គណៈគ្រប់គ្រង គឺជាអ្នកទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ មតិយោបល់របស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ពុំគ្របដណ្តប់លើព័ត៌មានផ្សេងៗនេះទេ ហើយយើងខ្ញុំក៏មិនបង្ហាញសេចក្តីសន្និដ្ឋានធានាអះអាងក្នុងទម្រង់ណាមួយទៅលើព័ត៌មានផ្សេងៗ នេះដែរ។

ទាក់ទងនឹងការងារសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ទំនួលខុសត្រូវរបស់យើងខ្ញុំ គឺការអានព័ត៌មានផ្សេងៗនេះ ហើយពិចារណា ថាតើព័ត៌មានផ្សេងៗនេះ មានភាពខុសគ្នាជាសារវន្ត ឬ ទេ ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ ឬ ចំណេះដឹងរបស់យើងខ្ញុំដែលទទួលបានពីការងារសវនកម្ម ឬ ថាតើព័ត៌មានផ្សេងៗនេះមានកំហុសឆ្គងជាសារវន្ត ឬទេ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្ត លើព័ត៌មានផ្សេងនេះ យើងខ្ញុំតម្រូវឲ្យរាយការណ៍តាមភាពជាក់ស្តែង។ យើងខ្ញុំ ពុំមានអ្វីដែលត្រូវរាយការណ៍ចំពោះព័ត៌មានផ្សេងនេះទេ។

### ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងក្រុមហ៊ុន ជាអ្នកទទួលខុសត្រូវចំពោះការរៀបចំ និង ការបង្ហាញទិដ្ឋភាពពិត និងត្រឹមត្រូវ នៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាម CIFRS for SMEs ហើយនិងទទួលខុសត្រូវដូចគ្នាផងដែរ ចំពោះប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងគិតថាមានសារៈប្រយោជន៍ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលពុំមានកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងជាអ្នកទទួលខុសត្រូវក្នុងការវាយតម្លៃលទ្ធភាព និរន្តរភាពអាជីវកម្មរបស់ក្រុមហ៊ុន និងធ្វើការលាតត្រដាង (ប្រសិនបើមាន) នូវបញ្ហាទាំងឡាយណាដែលទាក់ទងនឹងនិរន្តរភាពអាជីវកម្ម និង ការប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្មនៅក្នុងប្រព័ន្ធគណនេយ្យរបស់ក្រុមហ៊ុន លើកលែងតែក្នុងករណីគណៈគ្រប់គ្រងមានបំណងរំលាយ ឬ បញ្ឈប់ប្រតិបត្តិការណ៍ក្រុមហ៊ុន ឬក៏គ្មានមធ្យោបាយជាក់លាក់ណាមួយទៀតក្រៅពីនេះ។

អ្នកទទួលបន្ទុកលើអភិបាលកិច្ច មានទំនួលខុសត្រូវក្នុងការត្រួតពិនិត្យមើលលើដំណើរការនៃការរាយការណ៍អំពីហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

### ការទទួលខុសត្រូវរបស់សវនករចំពោះសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដែលសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុទាំងមូលមិនមានកំហុសឆ្គងជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ ហើយធ្វើការចេញផ្សាយរបាយការណ៍របស់សវនករដែលរួមមានមតិយោបល់របស់យើងខ្ញុំ។ ការធានាអះអាងដែលសមហេតុផល គឺជាការធានាអះអាងកម្រិតខ្ពស់មួយ ប៉ុន្តែមិនមែនជាការធានាថាការងារសវនកម្មដែលប្រព្រឹត្តទៅ ដោយអនុលោមតាម CISAs តែងតែរកឃើញកំហុសឆ្គងជាសារវន្តដែលមាននោះទេ។ កំហុសឆ្គងអាចកើតចេញពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ និងត្រូវបានចាត់ទុកថាជាសារវន្ត ប្រសិនបើកំហុសឆ្គងទាំងអស់នោះ (តែមួយ ឬ បញ្ចូលគ្នាជារួម) ដែលអាចមានឥទ្ធិពលលើការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ដោយផ្អែកលើមូលដ្ឋានរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

### ការទទួលខុសត្រូវរបស់សវនករចំពោះសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

ជាផ្នែកមួយនៃការងារសវនកម្មដែលអនុលោមតាម CISAs យើងខ្ញុំបានធ្វើការវិនិច្ឆ័យ និង រក្សានូវចម្ងល់ប្រកបដោយវិជ្ជាជីវៈក្នុងដំណើរការសវនកម្ម។ យើងខ្ញុំក៏បាន៖

- កំណត់ និង វាយតម្លៃហានិភ័យនៃកំហុសឆ្គងជាសារវន្ត នៃរបាយការណ៍ហិរញ្ញវត្ថុ ដែលបណ្តាលមកពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ បង្កើត និង អនុវត្តនីតិវិធីសវនកម្មដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ ហើយប្រមូលភស្តុតាងសវនកម្មឲ្យបានគ្រប់គ្រាន់ និង សមស្របសម្រាប់ផ្តល់ជាមូលដ្ឋានក្នុងការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំមានកម្រិតខ្ពស់ជាង កំហុសឆ្គងដែលបណ្តាលមកពីការភាន់ច្រឡំ ព្រោះថាការក្លែងបន្លំអាចពាក់ព័ន្ធនឹងការឃុបឃិត ការបន្លំ ការលុបចេញដោយចេតនា ការរាយការណ៍មិនត្រឹមត្រូវ ឬ មិនគោរពតាមប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធនឹងការងារសវនកម្ម ដើម្បីបង្កើតជានីតិវិធីសវនកម្ម ដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនសម្រាប់គោលបំណងដើម្បីបញ្ចេញមតិយោបល់លើប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុនទេ។
- វាយតម្លៃភាពសមស្របនៃគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និង ភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការបង្ហាញដែលជាប់ទាក់ទងផ្សេងទៀត ដែលធ្វើឡើងដោយគណៈគ្រប់គ្រង។
- ធ្វើសេចក្តីសន្និដ្ឋានទៅលើភាពសមស្រប នៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្មរបស់គណៈគ្រប់គ្រងនៅក្នុងប្រព័ន្ធគណនេយ្យ និងតាមរយៈភស្តុតាងសវនកម្មដែលទទួលបាន យើងខ្ញុំធ្វើការសន្និដ្ឋានលើវត្តមាននៃភាពមិនប្រាកដប្រជា ជាសារវន្តទាក់ទងនឹងព្រឹត្តិការណ៍ ឬ កាលៈទេសៈទាំងឡាយណា ដែលនាំឲ្យមានការសង្ស័យជាសារវន្តទៅលើនិរន្តរភាពនៃដំណើរការអាជីវកម្មរបស់ក្រុមហ៊ុន។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានវត្តមាននៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំតម្រូវឲ្យទាញចំណាប់អារម្មណ៍ក្នុងរបាយការណ៍សវនករលើកំណត់សម្គាល់ពាក់ព័ន្ធដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬ ប្រសិនបើកំណត់សម្គាល់នេះពុំមានលក្ខណៈគ្រប់គ្រាន់ទេនោះ យើង

ខ្ញុំនឹងធ្វើការកែប្រែមតិយោបល់របស់យើងខ្ញុំ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺពឹងផ្អែកលើភស្តុតាងសវនកម្មដែលទទួលបានរហូតដល់កាលបរិច្ឆេទរបាយការណ៍សវនករ។ តែទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬ កាលៈទេសៈនាពេលអនាគត ក៏អាចបង្កឲ្យក្រុមហ៊ុនមិនអាចបន្តនិរន្តរភាពរបស់អាជីវកម្មបានផងដែរ។

- វាយតម្លៃការដាក់បង្ហាញ ទម្រង់ និង មាតិកាទាំងស្រុងនៃរបាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងកំណត់ សម្គាល់ផ្សេងៗ និង វាយតម្លៃថារបាយការណ៍ហិរញ្ញវត្ថុ តំណាងឲ្យប្រតិបត្តិការ និង ព្រឹត្តិការណ៍ដែលជាមូលដ្ឋានដើម្បីសម្រេចបាននូវការបង្ហាញដ៏ត្រឹមត្រូវ។

**ការទទួលខុសត្រូវរបស់សវនករចំពោះសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)

ក្នុងចំណោមបញ្ហាដទៃទៀត យើងខ្ញុំបានទំនាក់ទំនងជាមួយអ្នកទទួលបន្ទុកលើអភិបាលកិច្ចអំពីវិសាលភាពដែលបានគ្រោងទុក និង ពេលវេលានៃការងារសវនកម្ម និង របកគំហើញសំខាន់ៗ រួមបញ្ចូលផងដែរនូវកង្វះខាតសំខាន់ៗ ទៅលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលយើងខ្ញុំរកឃើញក្នុងពេលធ្វើសវនកម្ម។




Associate Partner

អ៊ីនស្ទ៍ អ៊េន យ៉ាំង (ខេមបូឌា)
ក្រុមហ៊ុនគណនេយ្យករជំនាញ
សវនករប្រតិស្រុត

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

## ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

| | កំណត់សម្គាល់ | ២០២២ | | ២០២១ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ ២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ ២) (ដូចបានចាត់ថ្នាក់ឡើងវិញ - កំណត់សម្គាល់លេខ២២) |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ និងសមតុល្យនៅធនាគារ សុទ្ធ | ៤ | ១០.២៨៣.២៣៨ | ៤២.៣៣៦.០៩១ | ២.៩៨៨.១៩១ | ១២.១៧៣.៨៩០ |
| ប្រាក់តម្កល់តាមបទប្បញ្ញត្តិ | ៥ | ១.០០០.០០០ | ៤.១១៧.០០០ | ៧៥០.០០០ | ៣.០៥៥.៥០០ |
| ឥណទាន និងបុរេប្រទានទៅអតិថិជន | ៦ | ៧៨.៩៥១.៧៧៧ | ៣២៥.០៤៤.៤៦៦ | ៦៩.០៤៩.៤៤០ | ២៨១.៣០៧.៤១៩ |
| ទ្រព្យសកម្មផ្សេងៗ | ៧ | ២០១.៤៨៨ | ៨២៩.៥២៧ | ២៦០.៥៨៨ | ១.០៦១.៦៣៦ |
| ទ្រព្យ និងបរិក្ខារ | ៨ | ១.៣៣៤.៥៩៤ | ៥.៤៩៤.៥២៣ | ៨១៥.៥០៤ | ៣.៣២២.៣៦៣ |
| ទ្រព្យសកម្មអរូបី | ៩ | ១.៦០១.១២៤ | ៦.៥៩១.៨២៨ | ១.៣៤១.០៩៣ | ៥.៤៦៣.៦១៣ |
| ពន្ធពន្យារជាទ្រព្យសកម្ម | ១០.៣ | ៣៨៦.០០៤ | ១.៥៨៩.១៧៨ | ៨១.៧២៥ | ៣៣២.៩៤៨ |
| **ទ្រព្យសកម្មសរុប** | | **៩៣.៧៥៨.២២៥** | **៣៨៦.០០២.៦១៣** | ៧៥.២៨៦.៥៤១ | ៣០៦.៧១៧.៣៦៩ |
| | | | | | |
| **មូលធន និងបំណុល** | | | | | |
| **បំណុល** | | | | | |
| ពន្ធលើប្រាក់ចំណូលត្រូវបង់ | ១០.២ | ៧៧៦.៣៥៥ | ៣.១៩៦.២៥៤ | ៧២២.៩៦៦ | ២.៩៤៥.៣៦៣ |
| ប្រាក់កម្ចី | ១១ | ៦៦.៨៨៩.៧៤៩ | ២៧៥.៣៨៥.០៩៧ | ៥៦.៦៩២.៣០៨ | ២៣០.៩៦៤.៤៦៣ |
| បំណុលផ្សេងៗ | ១២ | ៤៧០.១៨២ | ១.៩៣៥.៧៣៩ | ៣៩៩.៧៧៣ | ១.៦២៨.៦៧៥ |
| **បំណុលសរុប** | | **៦៨.១៣៦.២៨៦** | **២៨០.៥១៧.០៩០** | ៥៧.៨១៥.០៤៧ | ២៣៥.៥៣៨.៥០១ |
| | | | | | |
| **មូលធន** | | | | | |
| ដើមទុន | ១៣ | ២០.០០០.០០០ | ៨០.០០០.០០០ | ១៥.០០០.០០០ | ៦០.០០០.០០០ |
| ប្រាក់ចំណេញបង្គរ | | ៥.៤០៥.៨១២ | ២២.២០៨.៦១៩ | ២.២៨០.៨៧៦ | ៩.៤៣៧.០០៥ |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | ១៤ | ២១៦.១២៧ | ៨៧៦.៧៣១ | ១៩០.៦១៨ | ៧៧២.៤៧៦ |
| លម្អៀងបង្គរពីការបកប្រែរូបិយប័ណ្ណ | | - | ២.៤០០.១៧៣ | - | ៩៦៩.៣៨៧ |
| មូលធនសរុប | | ២៥.៦២១.៩៣៩ | ១០៥.៤៨៥.៥២៣ | ១៧.៤៧១.៤៩៤ | ៧១.១៧៨.៨៦៨ |
| **មូលធន និងបំណុលសរុប** | | **៩៣.៧៥៨.២២៥** | **៣៨៦.០០២.៦១៣** | ៧៥.២៨៦.៥៤១ | ៣០៦.៧១៧.៣៦៩ |

# របាយការណ៍លទ្ធផលពេញលេញ

## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

| | កំណត់សម្គាល់ | ២០២២ | | ២០២១ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ ២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ ២) |
| | | | | (ដូចបានចាត់ថ្នាក់ឡើងវិញ - កំណត់សម្គាល់លេខ២២) | |
| ចំណូលការប្រាក់ | ១៥ | ១២.៨១៣.៦៩៣ | ៥២.៣៦៩.៥៦៣ | ៨.៨៩៨.៧៦៥ | ៣៦.២០០.១៧៦ |
| ចំណាយការប្រាក់ | ១៦ | (២.៧០២.០៤៤) | (១១.០៤៣.២៥៤) | (១.៣៧១.៣០២) | (៥.៥៧៨.៤៥៧) |
| **ចំណូលការប្រាក់សុទ្ធ** | | **១០.១១១.៦៤៩** | **៤១.៣២៦.៣០៩** | ៧.៥២៧.៤៦៣ | ៣០.៦២១.៧១៩ |
| កម្រៃ និងសេវាជើងសារ | ១៧ | (៣៤៨.០៧១) | (១.៤២២.៥៦៦) | (២៥៧.៦៨៦) | (១.០៤៨.២៦៦) |
| ចំណូលប្រតិបត្តិការផ្សេងៗ | ១៨ | ៦៩២.៤០២ | ២.៨២៩.៨៤៧ | ៤៥៣.៣៩៦ | ១.៨៤៤.៤១៥ |
| **ចំណូលប្រតិបត្តិការសរុប** | | **១០.៤៥៥.៩៨០** | **៤២.៧៣៣.៥៩០** | ៧.៧២៣.១៧៣ | ៣១.៤១៧.៨៦៨ |
| ចំណាយទូទៅ និងរដ្ឋបាល | ១៩ | (៥.៥៨៨.៦៧៦) | (២២.៨៤០.៩១៩) | (៤.១៩៨.១១២) | (១៧.០៧៧.៩២០) |
| ការកត់ត្រាបញ្ច្រាស់(សំវិធានធន) នៃសមតុល្យនៅធនាគារផ្សេងៗ | | ១០.៩៦២ | ៤៤.៨០២ | (១៧.៧៦៧) | (៧២.២៧៦) |
| សំវិធានធនលើការបាត់បង់ឥណទាន និងបុរេប្រទាន | ៦ | (១.១៣១.៤៩៤) | (៤.៦២៤.៤១៦) | (៤៧២.៣៤៧) | (១.៩២១.៥០៨) |
| **ចំណេញមុនគិតពន្ធលើប្រាក់ចំណូល** | | **៣.៧៤៦.៧៧២** | **១៥.៣១៣.០៥៧** | ៣.០៣៤.៩៤៧ | ១២.៣៤៦.១៦៤ |
| ចំណាយពន្ធលើប្រាក់ចំណូល | ១០ | (៥៩៦.៣២៧) | (២.៤៣៧.១៨៨) | (៧២៨.៦០៦) | (២.៩៦៣.៩៦៩) |
| **ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ** | | **៣.១៥០.៤៤៥** | **១២.៨៧៥.៨៦៩** | ២.៣០៦.៣៤១ | ៩.៣៨២.១៩៥ |
| **ចំណូលលម្អិតផ្សេងៗ៖** | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | ១.៤៣០.៧៨៦ | | ៧២៣.៦២៩ |
| **ចំណូលពេញលេញសរុប** | | **៣.១៥០.៤៤៥** | **១៤.៣០៦.៦៥៥** | ២.៣០៦.៣៤១ | ១០.១០៥.៨២៤ |

# របាយការណ៍បម្រែបម្រួលមូលធន

## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

| | ដើមទុន | | ចំណេញរក្សាទុក | | ប្រាក់បម្រុងតាមបទប្បញ្ញត្តិ (កំណត់សម្គាល់លេខ ១៤) | | លម្អៀងបង្គរពីការបកប្រែរូបិយប័ណ្ណ | សរុប | |
|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | ១៥.០០០.០០០ | ៦០.០០០.០០០ | ២.២៨០.៨៧៦ | ៩.៤៣៧.០០៥ | ១៩០.៦១៨ | ៧៧២.៤៧៦ | ៩៦៩.៣៨៧ | ១៧.៤៧១.៤៩៤ | ៧១.១៧៨.៨៦៨ |
| ដើមទុនបន្ថែម | ៥.០០០.០០០ | ២០.០០០.០០០ | - | - | - | - | - | ៥.០០០.០០០ | ២០.០០០.០០០ |
| ចំណេញក្នុងការិយបរិច្ឆេទ | - | - | ៣.១៥០.៤៤៥ | ១២.៨៣៥.៨៦៩ | - | - | - | ៣.១៥០.៤៤៥ | ១២.៨៣៥.៨៦៩ |
| ផ្ទេរទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | (២៥.៥០៩) | (១០៤.២៥៥) | ២៥.៥០៩ | ១០៤.២៥៥ | - | - | - |
| លម្អៀងពីបកប្រែរូបិយប័ណ្ណ | - | - | - | - | - | - | ១.៤៣០.៧៨៦ | - | ១.៤៣០.៧៨៦ |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **២០.០០០.០០០** | **៨០.០០០.០០០** | **៥.៤០៥.៨១២** | **២២.២០៨.៦១៩** | **២១៦.១២៧** | **៨៧៦.៧៣១** | **២.៤០០.១៧៣** | **២៥.៦២១.៩៣៩** | **១០៥.៤៨៥.៥២៣** |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២១ | ១៥.០០០.០០០ | ៦០.០០០.០០០ | ១៣.២៦៣ | ២១២.៣៥៦ | ១៥១.៨៩០ | ៦១៤.៩៣០ | ២៤៥.៧៥៨ | ១៥.១៦៥.១៥៣ | ៦១.០៧៣.០៤៤ |
| ចំណេញក្នុងការិយបរិច្ឆេទ | - | - | ២.៣០៦.៣៤១ | ៩.៣៨២.១៩៥ | - | - | | ២.៣០៦.៣៤១ | ៩.៣៨២.១៩៥ |
| ផ្ទេរទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | (៣៨.៧២៨) | (១៥៧.៥៤៦) | ៣៨.៧២៨ | ១៥៧.៥៤៦ | | - | - |
| លម្អៀងពីការបកប្រែរូបិយប័ណ្ណ | - | - | - | - | - | - | ៧២៣.៦២៩ | - | ៧២៣.៦២៩ |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | **១៥.០០០.០០០** | **៦០.០០០.០០០** | **២.២៨០.៨៧៦** | **៩.៤៣៧.០០៥** | **១៩០.៦១៨** | **៧៧២.៤៧៦** | **៩៦៩.៣៨៧** | **១៧.៤៧១.៤៩៤** | **៧១.១៧៨.៨៦៨** |

# របាយការណ៍លំហូរសាច់ប្រាក់

## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

| | កំណត់សម្គាល់ | ២០២២ | | ២០២១ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ ២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ ២) |
| **សកម្មភាពប្រតិបត្តិការ** | | | | | |
| ចំណេញមុនគិតពន្ធលើប្រាក់ចំណូល | | ៣.៧៤៦.៧៧២ | ១៥.៣១៣.០៥៧ | ៣.០៣៤.៩៤៧ | ១២.៣៤៦.១៦៤ |
| *និយ័តកម្មសម្រាប់៖* | | | | | |
| រំលស់ | ៨,៩ | ៤១៤.១៦៣ | ១.៦៩២.៦៨៣ | ២៦១.៩៣៥ | ១.០៦៥.៥៥២ |
| សំវិធានធនសម្រាប់លើការបាត់បង់ឥណទាន និងសមតុល្យនៅធនាគារផ្សេងៗ | ៤,៦ | ១.១២០.៥៣៣ | ៤.៥៧៩.៦១៨ | ៤៩០.១១៤ | ១.៩៩៣.៧៨៤ |
| ចំណាយការប្រាក់ | ១៦ | ២.៧០២.០៤៤ | ១១.០៤៣.២៥៤ | ១.៣៧១.៣០២ | ៥.៥៧៨.៤៥៧ |
| ចំណូលការប្រាក់ | ១៥ | (១២.៨១៣.៦៩៣) | (៥២.៣៦៩.៥៦៣) | (៨.៨៩៨.៧៦៥) | (៣៦.២០០.១៧៦) |
| ខាតពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | | ១.៤៤០ | ៥.៨៨៣ | ៧២៥ | ២.៩៤៩ |
| *បម្រែបម្រួលក្នុងប្រតិបត្តិការទ្រព្យសកម្ម និងបំណុល៖* | | | | | |
| ប្រាក់តម្កល់តាមបទប្បញ្ញត្តិ | ៥ | (២៥០.០០០) | (១.០២១.៧៥០) | - | - |
| ឥណទាន និងបុរេប្រទានទៅអតិថិជន | ៦ | (១០.៨៥៦.០៦៦) | (៤៤.៣៦៨.៧៤២) | (២៨.៧៩៦.១៦២) | (១១៧.១៤២.៧៨៧) |
| ទ្រព្យសកម្មផ្សេងៗ | ៧ | ៥៩.១០០ | ២៤១.៥៤២ | (៩៣.១១០) | (៣៧៨.៧៧១) |
| បំណុលផ្សេងៗ | ១២ | ៧០.៤០៩ | ២៨៧.៧៦២ | ២០៥.៥៧២ | ៨៣៦.២៦៧ |
| **លំហូរសាច់ប្រាក់បានប្រើក្នុងសកម្មភាពប្រតិបត្តិការ** | | **(១៥.៨០៥.២៩៩)** | **(៦៤.៥៩៦.២៥៦)** | **(៣២.៤២៣.៤៤២)** | **(១៣១.៨៩៨.៥៦១)** |
| ការប្រាក់ទទួលបាន | | ១២.៦៣៥.៨៥៩ | ៥១.៦៤២.៧៥៦ | ៨.០៣៧.២៥៨ | ៣២.៦៩៥.៥៦៦ |
| ពន្ធលើប្រាក់ចំណូលដែលទូទាត់ | ១០.២ | (៨៤៧.២១៧) | (៣.៤៦២.៥៧៦) | (៤០១.៨៩៥) | (១.៦៣៤.៩០៩) |
| **លំហូរសាច់ប្រាក់សុទ្ធក្នុងសកម្មភាពប្រតិបត្តិការ** | | **(៤.០១៦.៦៥៧)** | **(១៦.៤១៦.០៧៦)** | **(២៤.៧៨៨.០៧៩)** | **(១០០.៨៣៧.៩០៤)** |
| **សកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យ និងបរិក្ខារ | ៨ | (៨៧០.៩១៧) | (៣.៥៥៩.៤៣៦) | (៤៧០.៨៩៧) | (១.៩១៥.៦០៩) |
| ការទិញទ្រព្យសកម្មអរូបី | ៩ | (៣៣៥.៣០៦) | (១.៣៧០.៣៩៦) | (១.៣៥៣.០២១) | (៥.៥០៤.០៨៩) |
| ចំណូលពីការលក់ទ្រព្យ និងបរិក្ខារ | | ១១.៤៩៩ | ៤៦.៩៩៨ | ២៧៣ | ១.១១១ |
| **លំហូរសាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពវិនិយោគ** | | **(១.១៩៤.៧២៣)** | **(៤.៨៨២.៨៣៤)** | **(១.៨២៣.៦៤៥)** | **(៧.៤១៨.៥៨៧)** |
| **សកម្មភាពហិរញ្ញប្បទាន** | | | | | |
| ចំណូលពីប្រាក់កម្ចី | ១១ | ២១.០០០.០០០ | ៨៥.៨២៧.០០០ | ៤២.៨៤៦.៣២៦ | ១៧៤.២៩៨.៨៥៤ |
| ការទូទាត់ប្រាក់កម្ចី | ១១ | (១១.១១៤.៥៦៩) | (៤៥.៤២៥.២៤៤) | (១៣.០០០.០០០) | (៥២.៨៨៤.០០០) |
| ការទូទាត់ការប្រាក់លើប្រាក់កម្ចី | ១១ | (២.៣៩០.០៣៤) | (៩.៧៦៨.០៦៩) | (១.៣៧១.៣០២) | (៥.៥៧៨.៤៥៧) |
| សាច់ប្រាក់បានពីការបន្ថែមមូលធន | ១៣ | ៥.០០០.០០០ | ២០.៤៣៥.០០០ | - | - |
| **លំហូរសាច់ប្រាក់សុទ្ធពីសកម្មភាពហិរញ្ញប្បទាន** | | **១២.៤៩៥.៣៩៧** | **៥១.០៦៨.៦៨៧** | **២៨.៤៧៥.០២៤** | **១១៥.៨៣៦.៣៩៧** |
| ការកើនឡើងនៃសាច់ប្រាក់សុទ្ធ | | ៧.២៨៤.០១៨ | ២៩.៧៦៩.៧៨១ | ១.៨៦៣.៣០០ | ៧.៥៧៩.៩០៦ |
| សាច់ប្រាក់ដើមការិយបរិច្ឆេទ | | ៣.០១៦.៣៤៧ | ១២.២៨៨.៥៩៧ | ១.១៥៣.០៤៧ | ៤.៦៦៤.០៧៧ |
| លម្អៀងពីការបកប្រែរូបិយប័ណ្ណ | | - | ៣៤៨.២២៤ | - | ៤៤.៦១៤ |
| **សាច់ប្រាក់ចុងការិយបរិច្ឆេទ** | ៤ | **១០.៣០០.៣៦៥** | **៤២.៤០៦.៦០២** | **៣.០១៦.៣៤៧** | **១២.២៨៨.៥៩៧** |

BNK Financial Group

# BNKC MFI Plc.

ទំនាក់ទំនង. ០២៣ ២១៣ ៩០០
អ៊ីមែល. hq.bnkcc@c.bnkcapital.net
គេហទំព័រ. https://www.bnkcmfi.com/
ហ្វេសប៊ុក. BNKC Cambodia MFI Plc.